# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ៦១

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្តាប់សក្ខីកម្មសាក្សីជំនាញ គឺលោក **ហង់រី ឡូកាដ** ដែលត្រូវបានតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីទាំងពីរ។[1] សាក្សីជំនាញ ក៏បានផ្តល់សក្ខីកម្មស្តីពីចំណេះដឹងរបស់គាត់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនានាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងពាក្យស្លោករបស់បក្សកុំម្មុយនីស្តកម្ពុជា។ បន្ទាប់ពីបញ្ចប់សក្ខីកម្មរបស់លោក **ហង់រី ឡូកាដ** រួចមក សាក្សីដែលមានអត្តលេខ 2-TCW-976 បានផ្តល់សក្ខីកម្មស្ថិតនៅក្រោមការប្រើប្រាស់ឈ្មោះជារហស្សនាម ដោយអនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីអំពីការរក្សាការសម្ងាត់របស់សាក្សីដែលកំពុងស្ថិតក្នុងដំណាក់កាលនៃដំណើរការស៊ើបសួរ។[2] សាក្សីរូបនេះ បានផ្តល់សក្ខីកម្មមានលក្ខណៈខុសគ្នាជាច្រើនទៅនឹងពេលវេលារបស់គាត់ដែលធ្វើជានីរសារ ក្នុងភូមិភាគពាយព្យ ហើយគាត់ក៏មានចំណេះតិចតួច ពាក់ព័ន្ធនឹងការបោសសម្អាតដែលត្រូវបានចោទប្រកាន់ថា កើតមានឡើងនៅទីតាំងនោះផងដែរ។ នៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះសាលាដំបូងបានរៀបចំកិច្ចប្រជុំ

---

[1] សាក្សីជំនាញ **ហង់រី ឡូកាដ** (2-TCE-90) បានផ្តល់សក្ខីកម្មនៅថ្ងៃទី២៨ ដល់២៩ ខែកក្កដា ឆ្នាំ២០១៦។ សម្រាប់អត្ថបទសង្ខេប ស្តីពីសក្ខីកម្មមុនៗរបស់គាត់ សូមមើល សំណុំរឿងលេខ០០២ វគ្គ២ របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម របាយការណ៍លេខ៦០ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥៧ (ចុះថ្ងៃទី២៦-២៩ ខែកក្កដា ឆ្នាំ២០១៦) ទំព័រ៥ ដល់៨។

[2] ការប្រើប្រាស់រហស្សនាមត្រូវបានអនុញ្ញាតក្រោមវិធាន ២៩.៤(ខ) នៃវិធានផ្ទៃក្នុង ដែលបានបញ្ញត្តថា៖ ការប្រើប្រាស់រហស្សនាម ឬការធ្វើសវនាការជាអសាធារណៈ ត្រូវអនុវត្តចំពោះសាក្សីទាំងឡាយណាដែលកំពុងស្ថិតក្នុងដំណាក់កាលនៃដំណើរការស៊ើបសួរនៅ **អ.វ.ត.ក** សូមមើល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពី “វិសោធនកម្មវិធានផ្ទៃក្នុងលើកទី៩” (ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥) ទំព័រ ៣០ ដល់៣១។

ស្តីពីការរៀបចំសវនាការ ដែលភាគច្រើនធ្វើឡើងជាសវនាការអសាធារណៈ ដើម្បីពិភាក្សាពីការរៀបចំកាលវិភាគ និងការទទួលយកឯកសារថ្មីៗជាច្រើនចូលទៅក្នុងសំណុំរឿង០០២ វគ្គ២ ដែលឯកសារទាំងនេះបានមកពីកិច្ចដំណើរការស៊ើបសួរ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ប្រ៊ីតនី អូលីណា ឆៅ (Britni Olina Chau), ខេតលីន កាហ្វហ្វ្រៀ (Caitlin McCaffrie), និន វុទ្ធី, តាយ លីណា, ធំ ស្ដាពរ, អាលីណា យូត្រាតា (Alina Utrata) និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៉ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University